# សិក្ខាសាលាតាមដានដំណើរការ JSIP

# វិធានការរឹតបន្តឹង ចំពោះផលិតផលក្លែងក្លាយនៅប្រទេសជប៉ុន

**ថ្ងៃទី9 ខែធ្នូ ឆ្នាំ2022 កម្ពុជា/ជប៉ុន**

បទបង្ហាញពីខាងប្រទេសជប៉ុន មេធាវី ហ៊ីរ៉ាណុ ស៊ីហ្គិតុស៊ី (Hirano Shigetoshi)

រៀបចំឯកសារដោយ មេធាវី ហ៊ីរ៉ាណុ ស៊ីហ្គិតុស៊ី (Hirano Shigetoshi) មេធាវី គីមឹរ៉ា ខូថារ៉ូ (Kimura Kotaro)
មេធាវី អ៊ីណុអ៊ុំអិ ស៊ូអ៊ីឈិ (Inoue Shuichi) មេធាវី ម៉ាស៊ុម៉ុតុ ខូតា (Matsumoto Kota)

# 1. ការប្រៀបធៀបជាមួយនឹងដែនច្បាប់ផ្សេងទៀត

## (1) ប្រភេទនៃវិធានការរឹតបន្តឹង

- បណ្តឹងរដ្ឋប្បវេណី
- បណ្តឹងព្រហ្មទណ្ឌ
- ការគ្រប់គ្រងរដ្ឋបាល

* ប្រព័ន្ធគ្រប់គ្រងព្រំដែនដោយរដ្ឋបាលគយ គឺស្ថិតនៅក្នុងដែនច្បាប់នីមួយៗដែលពិចារណានៅខាងក្រោម ដូច្នេះ យើងនឹងធ្វើការប្រៀបធៀបក្រៅអំពីប្រព័ន្ធគ្រប់គ្រងព្រំដែនដោយរដ្ឋបាលគយ។

# 1. ការប្រៀបធៀបជាមួយនឹងដែនច្បាប់ផ្សេងទៀត

## (2) លំនាំដែលផ្លូវទាំង3ស្ថិតនៅរួមគ្នា

- បណ្ដឹងរដ្ឋប្បវេណី (ផ្លូវរដ្ឋប្បវេណី)
- បណ្ដឹងព្រហ្មទណ្ឌ (ផ្លូវព្រហ្មទណ្ឌ)
- ការគ្រប់គ្រងរដ្ឋបាល (ផ្លូវរដ្ឋបាល)

⇒ ចិន វៀតណាម ជាដើម

(ប៉ុន្តែ នៅប្រទេសវៀតណាម ការគ្រប់គ្រងរដ្ឋបាលគឺជាគោលសំខាន់)

# 1. ការប្រៀបធៀបជាមួយនឹងដែនច្បាប់ផ្សេងទៀត

## (3) លំនាំដែលតែងតែប្រទះឃើញជាទូទៅនៅបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ ក្រៅពីប្រទេសវៀតណាម

- បណ្ដឹងរដ្ឋប្បវេណី
- ស្ថាប័នរដ្ឋបាលគឺជាកន្លែងទទួលសំណុំរឿង ហើយតុលាការគឺជាកន្លែងដែលដោះស្រាយសំណុំរឿងព្រហ្មទណ្ឌ

⇒ ថៃ ម៉ាឡេស៊ី កម្ពុជា ហ្វីលីពីន ឥណ្ឌូនេស៊ី ជាដើម

# 1. ការប្រៀបធៀបជាមួយនឹងដែនច្បាប់ផ្សេងទៀត

## (4)លំនាំនៅប្រទេសជប៉ុន

- បណ្ដឹងរដ្ឋប្បវេណី
- បណ្ដឹងព្រហ្មទណ្ឌ

⇒ សហរដ្ឋអាមេរិច ឥណ្ឌា សិង្ហបុរី ជាដើម

# 1. ការប្រៀបធៀបជាមួយនឹងដែនច្បាប់ផ្សេងទៀត

## (5)លក្ខណៈពិសេសនៅប្រទេសជប៉ុន

* នៅប្រទេសជប៉ុន ក្រៅពីប្រព័ន្ធគ្រប់គ្រងព្រំដែនដោយរដ្ឋបាលគយ គឺ**គ្មាន**ប្រព័ន្ធគ្រប់គ្រងលក្ខណៈរដ្ឋបាលទៅលើផលិតផលក្លែងក្លាយនោះទេ

* ផ្នែកកិច្ចការងារ ហៅថា ការិយាល័យប៉ាតង់ ផ្នែកសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ គឺមានតួនាទីទទួលការពិគ្រោះបញ្ហាទាក់ទងនឹងផលិតផលក្លែងក្លាយនិងផលិតផលរំលោភកម្មសិទ្ធិបញ្ញា ពីសំណាក់អ្នកមានសិទ្ធិនៅប្រទេសជប៉ុន ប៉ុន្តែ គឺ**សន្ទុតថាជាករណីរងគ្រោះដោយសារផលិតផលក្លែងក្លាយនិងផលិតផលរំលោភកម្មសិទ្ធិបញ្ញានៅក្រៅប្រទេស**

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (1)ចំនួនករណីនៃបណ្តឹងរដ្ឋប្បវេណីទូទៅទាក់ទងនឹងកម្មសិទ្ធិបញ្ញា នៅសាលាដំបូង (សិទ្ធិពាណិជ្ជសញ្ញា សិទ្ធិអ្នកនិពន្ធ ជាដើម)

| | សិទ្ធិពាណិជ្ជសញ្ញា | សិទ្ធិអ្នកនិពន្ធ*1 | ច្បាប់ស្តីពីការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់*2 | ផ្សេងៗទៀត*3 | ចំនួនសរុប |
|---|---|---|---|---|---|
| ឆ្នាំ2020 | 68 | 167 | 75 | 183 | 493 |
| ឆ្នាំ2021 | 66 | 281 | 117 | 147 | 611 |

ប្រភព : "ស្ថានភាពសង្ខេបស្តីពីសំណុំរឿងរដ្ឋប្បវេណីនិងរដ្ឋបាលទាក់ទងនឹងកម្មសិទ្ធិបញ្ញាសម្រាប់ឆ្នាំ2020" (ទស្សនាវដ្តីច្បាប់សម្រាប់ខែ12 ឆ្នាំ2020)
"ស្ថានភាពសង្ខេបស្តីពីសំណុំរឿងរដ្ឋប្បវេណីនិងរដ្ឋបាលទាក់ទងនឹងកម្មសិទ្ធិបញ្ញាសម្រាប់ឆ្នាំ2021" (ទស្សនាវដ្តីច្បាប់សម្រាប់ខែ12 ឆ្នាំ2021)

*1 លើកលែងសិទ្ធិអ្នកបង្កើតកម្មវិធី
*2 រួមទាំងសំណុំរឿងរំលោភការសម្ងាត់ពាណិជ្ជកម្ម
*3 សិទ្ធិប៉ាតង់ កម្មសិទ្ធិលើគំនិតច្នៃប្រឌិតថ្មីចំពោះរចនាសម្ព័ន្ធផលិតផល កម្មសិទ្ធិលើក្បាច់រចនា សិទ្ធិអ្នកបង្កើតកម្មវិធី "ច្បាប់ពាណិជ្ជកម្មនិងផ្សេងៗទៀត"

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្ដឹងរដ្ឋប្បវេណី)

## (2)លក្ខណៈពិសេស

- នៅក្នុងវិធានការរឹតបន្តឹងចំពោះការរំលោភសិទ្ធិពាណិជ្ជសញ្ញានៅប្រទេសជប៉ុន **បណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ដោតជាសំខាន់**
- នីតិវិធីរួមមាន **បណ្ដឹងអង្គសេចក្ដី**និង**ការចាត់ចែងជាបណ្ដោះអាសន្ន**
- ការទាមទារនៅក្នុងបណ្ដឹងអង្គសេចក្ដី

  រួមមាន **①ការបញ្ឈប់សកម្មភាព ②សំណងការខូចខាត ③ការបញ្ឈប់សកម្មភាព+សំណងការខូចខាត** ហើយបន្ថែមលើចំណុចខាងលើ ក៏រួមមាន **④ចំណាត់ការស្ដារទំនុកចិត្ត(ការប្រកាសសុំអភ័យទោស) ⑤ការទាមទារកម្ទេចចោលនូវធាតុផ្សំនៃវត្ថុរំលោភសិទ្ធិជាអាទិ៍** ផងដែរ
- ការទាមទារនៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន គឺមានតែ **①ការបញ្ឈប់សកម្មភាព** ប៉ុណ្ណោះ

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (2)លក្ខណៈពិសេស

នៅក្នុងបណ្តឹងរដ្ឋប្បវេណី ចំណុចវិវាទគឺស្ថិតនៅត្រង់ការប្តឹងតវ៉ាអំពីថាតើសិទ្ធិពាណិជ្ជសញ្ញាគ្មានសុពលភាពដែរឬទេ ឬ ទាក់ទងនឹងភាពប្រហាក់ប្រហែលនៃម៉ាក ជាដើម

- ចំពោះផលិតផលរំលោភសិទ្ធិយ៉ាងច្បាស់លាស់ ដែលសំដៅទៅលើផលិតផលក្លែងបន្លំម៉ាកល្បី (ផលិតផលរំលោភសិទ្ធិពាណិជ្ជសញ្ញាយ៉ាងច្បាស់លាស់) ឬ ផលិតផលរំលោភកម្មសិទ្ធិបញ្ញា (ផលិតផលរំលោភសិទ្ធិអ្នកនិពន្ធយ៉ាងច្បាស់លាស់) គឺគ្មានចំណុចវិវាទនៅក្នុងច្បាប់នោះទេ ដូច្នេះ នៅក្នុងបណ្តឹងរដ្ឋប្បវេណី ការប្តឹងតវ៉ាគឺមានតិច។
- ដូច្នេះ ករណីជាបណ្តឹងរដ្ឋប្បវេណី ជាធម្មតា ចុងចម្លើយនឹងប្តឹងតវ៉ាអំពីការរំលោភសិទ្ធិ
- ផ្ទុយទៅវិញ ករណីដែលចុងចម្លើយមិនប្តឹងតវ៉ាថាជាការរំលោភសិទ្ធិ ភាគច្រើនគឺត្រូវបានដោះស្រាយតាមរយៈការជជែកគ្នារវាងភាគីដែលពាក់ព័ន្ធ មុននឹងមានការដាក់ពាក្យបណ្តឹង (លើកលែងករណីជាផលិតផលក្លែងបន្លំម៉ាកល្បីនិងផលិតផលរំលោភកម្មសិទ្ធិបញ្ញា)

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (3)នីតិវិធី និង ដែនសមត្ថកិច្ច

[ការដាក់ជូននូវពាក្យបណ្តឹង]

ការដាក់ជូននូវពាក្យបណ្តឹងទៅកាន់តុលាការដែលមានសមត្ថកិច្ច

[ដែនសមត្ថកិច្ច]

ចំពោះបណ្តឹងទាក់ទងនឹងសិទ្ធិប៉ាតង់ជាដើម គឺស្ថិតក្រោមដែនសមត្ថកិច្ចរបស់សាលាដំបូងក្រុងតូក្យូ ឬ សាលាដំបូងក្រុងអូសាកា ប៉ុន្តែ ចំពោះបណ្តឹងរំលោភសិទ្ធិពាណិជ្ជសញ្ញាក៏អាចត្រូវបានពិនិត្យដោយសាលាដំបូងផ្សេងៗទៀតផងដែរ

⇒ យ៉ាងណាមិញ ការដាក់ពាក្យបណ្តឹងគឺមានទំនោរប្រមូលផ្តុំនៅ សាលាដំបូងក្រុងតូក្យូនិង សាលាដំបូងក្រុងអូសាកា ដែលមានផ្នែកជំនាញកម្មសិទ្ធិបញ្ញា (ដែនសមត្ថកិច្ចក្រោមជម្រើស។ ច្បាប់ស្តីពីបណ្តឹងរដ្ឋប្បវេណីមាត្រាទី6-2)

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (4)ដំណើរការនៃបណ្តឹងទាក់ទងនឹងកម្មសិទ្ធិបញ្ញា




【ប្រភព: គេហទំព័រនៃសាលាឧទ្ធរណ៍កម្មសិទ្ធិបញ្ញា
（https://www.ip.courts.go.jp/tetuduki/jurisdiction/index.html）】

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (5)ការអនុវត្តដោយបង្ខំ

### ក. នីតិវិធីសម្រាប់ការចាប់ផ្តើមអនុវត្ត

- ចាំបាច់ត្រូវមានលិខិតបំណុល (សាលក្រមស្ថាពរ សាលក្រមដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន កំណត់ហេតុស្តីពីការសះជានៅក្នុងការជំនុំជម្រះ ជាដើម)

- ការផ្តល់រូបមន្តអនុវត្តទៅក្នុងលិខិតបំណុល

  នៅក្នុងប្រព័ន្ធអនុវត្តសំណុំរឿងរដ្ឋប្បវេណីនៅប្រទេសជប៉ុន គឺមានការបែងចែករវាងតុលាការដែលសម្រេចទៅលើការមានឬគ្មានសិទ្ធិ និង តុលាការដែលសម្រេចអនុវត្តសិទ្ធិដែលមាន ហើយលិខិតបំណុលដែលកើតឡើងគឺនឹងមិនមែនត្រូវបានទទួលស្គាល់លើអានុភាពអនុវត្តបានភ្លាមៗគ្រប់ករណីទាំងអស់នោះទេ ដូច្នេះគឺចាំបាច់ត្រូវមានការសំអាងពីក្រឡាបញ្ជីតុលាការដែលស្ថិតនៅក្នុងតុលាការដែលសម្រេចទៅលើការមានឬគ្មានសិទ្ធិ

- ការដាក់ពាក្យស្នើសុំនីតិវិធីអនុវត្តទៅកាន់តុលាការអនុវត្ត (ស្ថាប័នយុត្តិធម៌ក្រោមប្រព័ន្ធចៅក្រមមួយរូបដែលត្រូវបានចាត់តាំងឱ្យស្ថិតនៅក្នុងសាលាដំបូង)

# 2. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងរដ្ឋប្បវេណី)

## (5)ការអនុវត្តដោយបង្ខំ

ខ. ការអនុវត្តដោយបង្ខំនៅក្នុងករណីសំណុំរឿងរំលោភពាណិជ្ជសញ្ញា

① ការបង្ខំដោយផ្ទាល់ ជាករណីដែលស្ថាប័នអនុវត្តផ្ទាក់ជាតិធ្វើសកម្មភាពអនុវត្តសិទ្ធិដោយផ្ទាល់

**ឧទាហរណ៍: ការអនុវត្តទាក់ទងនឹងប្រាក់កាស (ចំពោះចំណាត់ការបញ្ឈប់សកម្មភាពរំលោភសិទ្ធិពាណិជ្ជសញ្ញាគឺមិនអាចអនុវត្តការបង្ខំដោយផ្ទាល់បានទេ)**

② ការអនុវត្តជំនួស ករណីដែលតម្រូវឱ្យម្ចាស់បំណុលឬតតិយជនធ្វើសកម្មភាពអនុវត្តសិទ្ធិ

① ការអនុវត្តដោយបង្ខំទាក់ទងនឹងកាតព្វកិច្ចដែលមានគោលដៅឱ្យធ្វើសកម្មភាពណាមួយ

**ឧទាហរណ៍: ការប្រកាសសុំអភ័យទោស ការកម្ទេចចោលនូវវត្ថុធាតុផ្សំដែលប្រើនៅក្នុងទង្វើរំលោភសិទ្ធិពាណិជ្ជសញ្ញា ការដកយកចេញនូវបរិក្ខារ ។ល។**

② ការអនុវត្តដោយបង្ខំទាក់ទងនឹងកាតព្វកិច្ចដែលមានគោលដៅមិនឱ្យធ្វើសកម្មភាពណាមួយ

**ឧទាហរណ៍: ការកម្ទេចចោលនូវផលិតផលរំលោភសិទ្ធិ នៅក្នុងករណីដែលនៅបន្តការផលិតនូវផលិតផលរំលោភ បំពាន ទោះក្រោយពេលដែលសាលក្រមសម្រេចឱ្យបញ្ឈប់សកម្មភាពបានចូលជាស្ថាពរហើយក៏ដោយ**

③ វិធានបង្ខំដោយប្រយោល ជាករណីដែលតម្រូវឱ្យកូនបំណុលខ្លួនឯងធ្វើសកម្មភាពអនុវត្តសិទ្ធិ និងបន្ថែមការបង្ខំផ្នែកផ្លូវចិត្តតាមរយៈការតម្រូវអោយសងជាប្រាក់

**ឧទាហរណ៍: ការដាក់បំណុលជាប្រាក់បង្ខំរហូតដល់ពេលបញ្ឈប់ទង្វើរំលោភសិទ្ធិពាណិជ្ជសញ្ញា**

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងព្រហ្មទណ្ឌ)

## (1)ទោសព្រហ្មទណ្ឌចំពោះការរំលោភសិទ្ធិពាណិជ្ជសញ្ញា

- ទោសរំលោភពាណិជ្ជសញ្ញា (ច្បាប់ស្តីពីពាណិជ្ជសញ្ញាមាត្រាទី78)

→មិនមែនជាការធ្វេសប្រហែស ប៉ុន្តែ ចាំបាច់ត្រូវតែជា**ចេតនា** គឺខុសពីទំនួលខុសត្រូវនៅក្នុងសំណុំរឿងរដ្ឋប្បវេណី

- **ការផ្តន្ទាទោសដាក់ពន្ធនាគារ 10 ឆ្នាំចុះក្រោម** ឬ**ការពិន័យជាប្រាក់ 1000 ម៉ឺនយេនចុះក្រោម** ឬ **ការអនុវត្តទោសត្រួតគ្នា**
- **បញ្ញត្តិពីរភាគី** (ច្បាប់ស្តីពីពាណិជ្ជសញ្ញាមាត្រាទី82ចំណុចទី1)

→ ករណីដែលអ្នកតំណាងនៃនីតិបុគ្គល ឬក៏ អ្នកជំនួស អ្នកស៊ីឈ្នួល ឬ បុគ្គលិកផ្សេងៗទៀតនៃនីតិបុគ្គលឬបុគ្គល បានប្រព្រឹត្តទង្វើរំលោភសិទ្ធិទាក់ទងនឹងការងាររបស់នីតិបុគ្គលឬបុគ្គលនោះ ការផ្តន្ទាទោសពិន័យក៏ត្រូវបានអនុវត្តចំពោះនីតិបុគ្គលឬបុគ្គលនោះផងដែរ។ ករណីជានីតិបុគ្គល ការពិន័យគឺ **3 រយលានយេន**ចុះក្រោម ហើយករណីជាបុគ្គល ការពិន័យគឺ **1 រយលានយេន**ចុះក្រោម

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្ដឹងព្រហ្មទណ្ឌ)

## (1) បម្រែបម្រួលនៃចំនួនសមាជិកមន្ត្រីទទួលសំណុំរឿងថ្មី* នៃអយ្យការសំណុំរឿងក្ដីរំលោភកម្មសិទ្ធិបញ្ញា (ការបំពានច្បាប់ស្ដីពីពាណិជ្ជសញ្ញា ការបំពានច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ)

ឆ្នាំ2001～ឆ្នាំ2020




* សំដៅទៅលើសមាជិកមន្ត្រីទទួលសំណុំរឿងដែលព្រះរាជអាជ្ញាបានទទួលស្គាល់ឬបានទទួលដោយផ្ទាល់ និង សំណុំរឿងដែលត្រូវបានបញ្ជូនឬផ្ញើពីមន្ត្រីនគរបាលយុត្តិធម៌ (រួមទាំងមន្ត្រីនគរបាលយុត្តិធម៌ពិសេសនិងមន្ត្រីត្រួតពិនិត្យនៃទីភ្នាក់ងារគយថ្នាក់ជាតិ)

[ប្រភព: "សៀវភៅលាតត្រដាងបទល្មើសឆ្នាំ2021"]

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងព្រហ្មទណ្ឌ)

## (2) ចំនួនករណីស្វែងរកឃើញជនល្មើសក្នុងសំណុំរឿងក្តីរំលោភកម្មសិទ្ធិបញ្ញា (ការបំពានច្បាប់ស្តីពីពាណិជ្ជសញ្ញា)




| | ឆ្នាំ2011 | ឆ្នាំ2012 | ឆ្នាំ2013 | ឆ្នាំ2014 | ឆ្នាំ2015 | ឆ្នាំ2016 | ឆ្នាំ2017 | ឆ្នាំ2018 | ឆ្នាំ2019 | ឆ្នាំ2020 |
|---|---|---|---|---|---|---|---|---|---|---|
| សំណុំរឿងបទល្មើសរំលោភសិទ្ធិពាណិជ្ជសញ្ញា | 236 | 260 | 241 | 247 | 316 | 304 | 302 | 309 | 316 | 280 |
| ក្នុងចំណោមនោះ គឺជាសំណុំរឿងបទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត | 141 | 161 | 158 | 174 | 248 | 250 | 249 | 265 | 255 | 210 |
| ភាគរយនៃសំណុំរឿងបទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត | 59.7% | 61.9% | 65.6% | 70.4% | 78.5% | 82.2% | 82.5% | 85.8% | 80.7% | 75.0% |

2011 2020

[ប្រភព: "អំពីស្ថានភាពស្វែងរកឃើញជនល្មើសក្នុងសំណុំរឿងបទល្មើសទាក់ទងនឹងសេដ្ឋកិច្ចរស់នៅជាអាទិ៍នៅឆ្នាំ2020" (ទីភ្នាក់ងារនគរបាល នាយកដ្ឋានសុវត្ថិភាពរស់នៅ មន្ត្រីគ្រប់គ្រងវិធានការ សេដ្ឋកិច្ចរស់នៅ)]

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្ដឹងព្រហ្មទណ្ឌ)

## (3) ចំនួនករណីស្វែងរកឃើញជនល្មើសក្នុងសំណុំរឿងក្ដីរំលោភកម្មសិទ្ធិបញ្ញា (ការបំពានច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ)




| | ឆ្នាំ2011 | ឆ្នាំ2012 | ឆ្នាំ2013 | ឆ្នាំ2014 | ឆ្នាំ2015 | ឆ្នាំ2016 | ឆ្នាំ2017 | ឆ្នាំ2018 | ឆ្នាំ2019 | ឆ្នាំ2020 |
|---|---|---|---|---|---|---|---|---|---|---|
| សំណុំរឿងបទល្មើសរំលោភសិទ្ធិពាណិជ្ជសញ្ញា | 194 | 196 | 240 | 270 | 239 | 238 | 172 | 169 | 141 | 112 |
| ក្នុងចំណោមនោះ គឺជាសំណុំរឿងបទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត | 164 | 160 | 209 | 224 | 215 | 217 | 153 | 149 | 123 | 102 |
| ភាគរយនៃសំណុំរឿងបទល្មើសដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត | 84.5% | 81.6% | 87.1% | 83.0% | 90.0% | 91.2% | 89.0% | 88.2% | 87.2% | 91.1% |

2011 2020

[ប្រភព: "អំពីស្ថានភាពស្វែងរកឃើញជនល្មើសក្នុងសំណុំរឿងបទល្មើសទាក់ទងនឹងសេដ្ឋកិច្ចរស់នៅជាអាទិ៍នៅឆ្នាំ2020" (ទីភ្នាក់ងារនគរបាល នាយកដ្ឋានសុវត្ថិភាពរស់នៅ មន្ត្រីគ្រប់គ្រងវិធានការ សេដ្ឋកិច្ចរស់នៅ)]

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងព្រហ្មទណ្ឌ)

## (4)លក្ខណៈពិសេស

- ទោសព្រហ្មទណ្ឌសម្រាប់ការរំលោភកម្មសិទ្ធិបញ្ញា ត្រូវបានអនុវត្តចំពោះតែករណីជា**បទល្មើសដោយចេតនា**ប៉ុណ្ណោះ។

  ⇒ ការផ្តន្ទាទោសជាទោសព្រហ្មទណ្ឌ គឺត្រូវបានកំណត់ក្រោមភាពជាក់ស្តែងចំពោះតែសំណុំរឿងក្តីដែលត្រូវបានទទួលស្គាល់ទៅលើភាពច្បាស់លាស់នៃអង្គហេតុស្តីអំពីទង្វើរំលោភសិទ្ធិនិងការប្រព្រឹត្តទង្វើនោះដោយចេតនា មានដូចជាទាក់ទងនឹងផលិតផលរំលោភសិទ្ធិយ៉ាងច្បាស់លាស់ ដែលសំដៅទៅលើ**ផលិតផលក្លែងបន្លំម៉ាកល្បី (ផលិតផលរំលោភសិទ្ធិពាណិជ្ជសញ្ញាយ៉ាងច្បាស់លាស់)** និង **ផលិតផលរំលោភកម្មសិទ្ធិបញ្ញា (ផលិតផលរំលោភសិទ្ធិអ្នកនិពន្ធយ៉ាងច្បាស់លាស់)** ជាអាទិ៍ប៉ុណ្ណោះ

- នៅក្នុងសំណុំរឿងបទល្មើសក្លែងបន្លំម៉ាកល្បី (ការបំពានច្បាប់ស្តីពីពាណិជ្ជសញ្ញា) ភាគច្រើនគឺជា**ករណីនាំចូលដោយសម្ងាត់**ពីក្រៅប្រទេស (ជាចម្បងពីប្រទេសចិននិងប្រទេសកូរ៉េ)

# 3. វិធានការរឹតបន្តឹងនៅប្រទេសជប៉ុន (បណ្តឹងព្រហ្មទណ្ឌ)

## (4)លក្ខណៈពិសេស

- នីតិវិធីសំណុំរឿងរដ្ឋប្បវេណីនិងនីតិវិធីសំណុំរឿងព្រហ្មទណ្ឌត្រូវបានបែងចែកពីគ្នាយ៉ាងតឹងរ៉ឹង។ ដូច្នេះ ជាគោលការណ៍ នៅក្នុងការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ គឺគ្មានប្រព័ន្ធដែលអនុវត្តការសងសំណងជាប្រាក់ចំពោះជនរងគ្រោះនោះទេ។

(សេចក្តីយោង) ក៏មានប្រព័ន្ធដែលហៅថា "ប្រព័ន្ធបទបញ្ជាសំណងការខូចខាត"ផងដែរ ប៉ុន្តែ សំណុំរឿងដែលជាគោលដៅត្រូវអនុវត្តប្រព័ន្ធនេះគឺស្ថិតក្រោមលក្ខខណ្ឌកំណត់ ហើយសំណុំរឿងទាក់ទងនឹងការរំលោភកម្មសិទ្ធិបញ្ញាគឺមិនមែនជាគោលដៅសម្រាប់ការអនុវត្តប្រព័ន្ធនេះទេ

- ម្យ៉ាងទៀត យោងតាមប្រព័ន្ធ ភស្តុតាងដែលលេចឡើងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌគឺមិនមែនថាមិនអាចប្រើប្រាស់នៅក្នុងបណ្តឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ករណីដូចនោះគឺមិនត្រូវបានអនុវត្តឡើយ

- រួមមាន**បទល្មើសដែលត្រូវការមានបណ្តឹងពីជនរងគ្រោះ** (បទល្មើសដែលចាំបាច់ត្រូវការមានការប្តឹងពីជនរងគ្រោះដើម្បីព្រះរាជអាជ្ញាអាចរៀបចំអនុវត្តបណ្តឹងអាជ្ញា) និង **បទល្មើសដែលមិនត្រូវការមានបណ្តឹងពីជនរងគ្រោះ**

ឧទាហរណ៍នៃបទល្មើសដែលត្រូវការមានបណ្តឹងពីជនរងគ្រោះ : បទល្មើសរំលោភបំពានលើ សិទ្ធិអ្នកនិពន្ធ* ការសម្ងាត់ពាណិជ្ជកម្ម (ច្បាប់ស្តីពីការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់) ។ល។

ឧទាហរណ៍នៃបទល្មើសដែលមិនត្រូវការមានបណ្តឹងពីជនរងគ្រោះ : បទល្មើសរំលោភបំពានលើ សិទ្ធិប៉ាតង់ កម្មសិទ្ធិលើគំនិតច្នៃប្រឌិតថ្មីចំពោះរចនាសម្ព័ន្ធផលិតផល កម្មសិទ្ធិលើក្បាច់រចនា សិទ្ធិពាណិជ្ជសញ្ញា ។ល។

＊ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2019ទៅ មួយផ្នែកត្រូវបានផ្លាស់ប្តូរទៅជាបទល្មើសដែលមិនត្រូវការមានបណ្តឹងពីជនរងគ្រោះ

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## (1) ស្ថានភាពនៃការបញ្ឈប់សកម្មភាពនៃផលិតផលរំលោភកម្មសិទ្ធិបញ្ញា នៅតំបន់ព្រំដែន




សមិទ្ធផលនៃការបញ្ឈប់សកម្មភាពនាំចូលនៅពាក់កណ្ដាលឆ្នាំដំបូងនៃឆ្នាំ 2022 គឺ **ក្នុង1ថ្ងៃជាមធ្យម 69ករណី 2235មុខទំនិញ**

[ប្រភព : គេហទំព័រនៃក្រសួងហិរញ្ញវត្ថុ (https://www.mof.go.jp)]

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## (2) ឧទាហរណ៍នៃផលិតផលដែលបានបញ្ឈប់សកម្មភាព




[នាឡិកា (ផលិតផលរំលោភសិទ្ធិពាណិជ្ជសញ្ញា)]



[សម្បកទូរសព្ទទំនើប (ផលិតផលរំលោភសិទ្ធិអ្នកនិពន្ធ)]

[ប្រភព : គេហទំព័រនៃក្រសួងហិរញ្ញវត្ថុ (https://www.mof.go.jp)]

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## (3)នីតិវិធីនៅក្នុងការដាក់ពាក្យស្នើសុំបញ្ជប់សកម្មភាពនាំចូល

ក. អាសយដ្ឋានផ្ញើពាក្យស្នើសុំ: រដ្ឋបាលគយណាមួយក្នុងចំណោមទីតាំងទាំង9នៅទូទាំងប្រទេស




[ប្រភព : គេហទំព័រនៃរដ្ឋបាលគយ ( https://www.customs.go.jp )]

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## ខ. សិទ្ធិដែលជាគោលដៅអនុវត្ត

សិទ្ធិប៉ាតង់ កម្មសិទ្ធិលើគំនិតច្នៃប្រឌិតថ្មីចំពោះរចនាសម្ព័ន្ធផលិតផល កម្មសិទ្ធិលើក្បាច់រចនា សិទ្ធិពាណិជ្ជសញ្ញា សិទ្ធិ(ក្បែរ)អ្នកនិពន្ធ សិទ្ធិអ្នកបណ្ដុះបណ្ដាល ច្បាប់ស្ដីពីការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់

cf នៅក្នុង**ការផ្ដល់ព័ត៌មានទាក់ទងនឹងការបញ្ឈប់សកម្មភាពនាំចូល** សិទ្ធិប្រើប្រាស់គំនូរបង្ហាញសៀគ្វីក៏ស្ថិតក្នុងគោលដៅនៃការគ្រប់គ្រងផងដែរ

## គ. ឯកសារភ្ជាប់

- ករណីទទួលបានលិខិតសាលក្រម/សេចក្ដីសម្រេចលើការចាត់ចែងជាបណ្ដោះអាសន្នពីតុលាការ គឺត្រូវភ្ជាប់ឯកសារនេះ ប៉ុន្តែ ក៏អាចប្រើប្រាស់**លិខិតកោសលវិច័យរបស់មេធាវីជាអាទិ៍**ផងដែរ ដោយនៅក្នុងការអនុវត្តជាក់ស្ដែង ភាគច្រើនគឺដាក់ពាក្យស្នើសុំដោយភ្ជាប់លិខិតកោសលវិច័យរបស់មេធាវីជាអាទិ៍
- ឯកសារដែលត្រូវការចាំបាច់គឺខុសគ្នាទៅតាមប្រភេទនៃសិទ្ធិៗ នៅក្នុងករណីជាការបំពានច្បាប់ស្ដីពីការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់ គឺចាំបាច់ត្រូវការ**លិខិតថ្លែងយោបល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងឧស្សាហកម្ម**ជាដាច់ខាត

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## (4)ករណីពិបាកសម្រេចទៅលើថាតើជាការរំលោភសិទ្ធិឬមិនមែន

### ក. នីតិវិធីទទួលស្គាល់

ប្រព័ន្ធដែលក្នុងករណីរដ្ឋបាលគយបានរកឃើញផលិតផលដែលសង្ស័យថាជាការរំលោភកម្មសិទ្ធិបញ្ញា រដ្ឋបាលគយត្រូវជូនដំណឹងអំពីបញ្ហានេះទៅដល់អ្នកមានសិទ្ធិនិងអ្នកនាំចូល ដើម្បីសុំការថ្លែងយោបល់និងបង្ហាញភស្តុតាងពីភាគីម្ខាងៗ រួចរដ្ឋបាលគយនឹងធ្វើការទទួលស្គាល់ថាជាផលិតផលរំលោភសិទ្ធិឬមិនមែន

### ខ. ប្រព័ន្ធសភាជំនាញ

ប្រព័ន្ធដែលក្នុងករណីពិបាកសម្រេចថាជាផលិតផលរំលោភសិទ្ធិឬមិនមែន គឺត្រូវជ្រើសរើស**សភាជំនាញ** (បុគ្គលដែលមានបទពិសោធន៍ផ្នែកចំណេះដឹង ដូចជា សាស្ត្រាចារ្យ មេធាវី ជាដើម) រួចស្តាប់ការថ្លែងយោបល់របស់បុគ្គលនោះ ដើម្បីធ្វើការវិនិច្ឆ័យ

# 4. ប្រព័ន្ធគ្រប់គ្រងព្រំដែននៅប្រទេសជប៉ុន

## (5)ការពង្រឹងបទប្បញ្ញត្តិនៃការហូរចូលផលិតផលក្លែងក្លាយពីក្រៅប្រទេស

ការលក់ផលិតផលពីសំណាក់អាជីវករបរទេសទៅកាន់អ្នកនាំចូលលក្ខណៈបុគ្គល គឺមិនធ្លាប់ត្រូវបានចាត់ចូលជាករណីរំលោភសិទ្ធិពាណិជ្ជសញ្ញាទេ ប៉ុន្តែ យោងតាមវិសោធនកម្មច្បាប់ស្តីពីពាណិជ្ជសញ្ញា (អនុម័ត នៅថ្ងៃទី1 ខែតុលា ឆ្នាំ2022) អាជីវករបរទេសក្នុងករណីខាងលើក៏ត្រូវបានសន្មតឱ្យទទួលខុសត្រូវចំពោះការរំលោភសិទ្ធិពាណិជ្ជសញ្ញានៅប្រទេសជប៉ុនផងដែរ។




[ប្រភព : គេហទំព័រនៃការិយាល័យប៉ាតង់ (https://www.jpo.go.jp )]

⇒ ចំពោះបណ្តឹងរដ្ឋប្បវេណីនិងបណ្តឹងព្រហ្មទណ្ឌ ក្រៅអំពីការបញ្ឈប់សកម្មភាពដោយរដ្ឋបាលគយ នៅខណៈពេលបច្ចុប្បន្ន គឺមិនទាន់មានការកំណត់ច្បាស់លាស់ថាតើត្រូវធ្វើចំណាត់ការយ៉ាងណានោះទេ

# 5. វិធានការវិតបន្តឹងចំពោះផលិតផលក្លែងក្លាយនៅលើប្រព័ន្ធអ៊ីនធឺណិត

## (1)ករណីអាសយដ្ឋាននិងឈ្មោះនៃអ្នករំលោភសិទ្ធិមានលក្ខណៈច្បាស់លាស់

- ក្នុងចំណោមការរំលោភសិទ្ធិនៅលើប្រព័ន្ធអ៊ីនធឺណិត ករណីជាការបរិហារកេរ្តិ៍ជាដើម ភាគច្រើនគឺមិនច្បាស់អំពីអាសយដ្ឋានឬឈ្មោះរបស់អ្នកផ្សព្វផ្សាយទេ ប៉ុន្តែ ករណីជាផលិតផលក្លែងក្លាយ (ការរំលោភសិទ្ធិពាណិជ្ជសញ្ញា) ភាគច្រើនគឺមានការបង្ហាញនូវអាសយដ្ឋានឬឈ្មោះរបស់អ្នករំលោភសិទ្ធិ
- ករណីអាសយដ្ឋាននិងឈ្មោះនៃអ្នករំលោភសិទ្ធិមានលក្ខណៈច្បាស់លាស់គឺអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីពីដំបូងតែម្តង

# 5. វិធានការតបន្ដឹងចំពោះផលិតផលក្លែងក្លាយនៅលើប្រព័ន្ធអ៊ីនធឺណិត

## (2)ករណីអាសយដ្ឋាននិងឈ្មោះនៃអ្នករំលោភសិទ្ធិមានលក្ខណៈមិនច្បាស់លាស់ (មុនវិសោធនកម្មច្បាប់)

① អនុវត្ត**ការទាមទារក្រៅតុលាការចំពោះភាគីផ្ដល់ខ្លឹមសារ(CP)** ដោយផ្អែកលើទិសដៅអនុវត្តដែលចែងដោយក្រុមប្រឹក្សាពិគ្រោះ (សហព័ន្ធនៃក្រុមអាជីវកម្មឯកជនច្រើន) មានដូចជា ទិសដៅអនុវត្តច្បាប់ស្ដីពីការកំណត់ទំនួលខុសត្រូវចំពោះភាគីផ្ដល់

↓

② ករណីមិនអនុវត្តការលុបចោលផ្អែកលើទិសដៅអនុវត្តទេ នោះនឹងមានការស្នើសុំ**ការចាត់ចែងជាបណ្ដោះអាសន្នចំពោះ CP** ដើម្បីទទួលបានអាសយដ្ឋានIP (IP Address) និង ត្រាពេលវេលា (Timestamp) (ការទាមទារបើកបង្ហាញព័ត៌មានអ្នកបញ្ចេញខ្លឹមសារ ផ្អែកលើច្បាប់ស្ដីពីការកំណត់ទំនួលខុសត្រូវចំពោះភាគីផ្ដល់)

ដោយសារអាចស្នើសុំការលុបចោលស្របពេលគ្នានោះដែរ ដូច្នេះ ប្រសិនបើត្រឹមតែជាការលុបចោលទំព័រ នោះគឺអាចសម្រេចបាននៅដំណាក់កាលនេះ

↓

③ ករណីទាមទារសំណងការខូចខាត គឺត្រូវស្វែងរកឱ្យឃើញនូវ**ភាគីផ្ដល់ការចូល(AP)** ដោយផ្អែកលើអាសយដ្ឋានIP និង ត្រាពេលវេលា ដែលទទួលបាននៅ② **រួចដាក់ពាក្យបណ្ដឹងអង្គសេចក្ដីចំពោះAP** ដើម្បីទាមទារការបើកបង្ហាញអាសយដ្ឋាននិងឈ្មោះរបស់អ្នករំលោភសិទ្ធិ (ការទាមទារបើកបង្ហាញព័ត៌មានអ្នកបញ្ចេញខ្លឹមសារ ផ្អែកលើច្បាប់ស្ដីពីការកំណត់ទំនួលខុសត្រូវចំពោះភាគីផ្ដល់)

↓

④ ដាក់ពាក្យ**បណ្ដឹងរដ្ឋប្បវេណីចំពោះអ្នករំលោភសិទ្ធិ** ដោយផ្អែកលើអាសយដ្ឋាននិងឈ្មោះដែលបានបើកបង្ហាញនៅខាងលើ

# 5. វិធានការតបន្តឹងចំពោះផលិតផលក្លែងក្លាយនៅលើប្រព័ន្ធអ៊ីនធឺណិត

## (3)ករណីអាសយដ្ឋាននិងឈ្មោះនៃអ្នករំលោភសិទ្ធិមានលក្ខណៈមិនច្បាស់លាស់ (ក្រោយវិសោធនកម្មច្បាប់)

① អនុវត្តការទាមទារក្រៅតុលាការចំពោះភាគីផ្តល់ខ្លឹមសារ(CP) ដោយផ្អែកលើទិសដៅអនុវត្តដែលចែងដោយក្រុមប្រឹក្សាពិគ្រោះ មានដូចជា ទិសដៅអនុវត្តច្បាប់ស្តីពីការកំណត់ទំនួលខុសត្រូវចំពោះភាគីផ្តល់

② + ③ ស្នើសុំការចេញបទបញ្ជាបើកបង្ហាញព័ត៌មានអ្នកបញ្ចេញខ្លឹមសារ(ច្បាប់ក្រោយវិសោធនកម្មមាត្រាទី8ចុះក្រោម) ស្របពេលនឹងបទបញ្ជាផ្តល់ព័ត៌មាន(ច្បាប់ក្រោយវិសោធនកម្មមាត្រាទី15) ចំពោះCP រួចស្នើសុំការចេញបទបញ្ជាបើកបង្ហាញព័ត៌មានអ្នកបញ្ចេញខ្លឹមសារ ចំពោះភាគីផ្តល់ការចូល(AP) ដែលស្វែងរកឃើញតាមរយៈព័ត៌មានដែលបានបើកបង្ហាញដោយCP (អាសយដ្ឋានIP និង ត្រាពេលវេលា គឺត្រូវបានបើកបង្ហាញពី CP ទៅកាន់ AP)
ភាគីផ្តល់ការចូល(AP)ត្រូវបើកបង្ហាញអាសយដ្ឋាននិងឈ្មោះរបស់អ្នករំលោភសិទ្ធិទៅដល់អ្នកដែលបានស្នើសុំ ដោយផ្អែកលើបទបញ្ជាបើកបង្ហាញ

**ការទាមទារចំពោះCP និង ការទាមទារចំពោះAP ត្រូវបានផ្លាស់ប្តូរទៅជាអាចអនុវត្តតាមនីតិវិធីនៃសំណុំរឿងមិនត្រូវការពាក្យបណ្តឹងតែមួយ**
**(វិសោធនកម្មច្បាប់ស្តីពីការកំណត់ទំនួលខុសត្រូវចំពោះភាគីផ្តល់ អនុម័តនៅថ្ងៃទី1 ខែតុលា ឆ្នាំ2022)**

④ ដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីចំពោះអ្នករំលោភសិទ្ធិ ដោយផ្អែកលើអាសយដ្ឋាននិងឈ្មោះដែលបានបើកបង្ហាញនៅខាងលើ

# សិក្ខាសាលាតាមដានដំណើរការ JSIP

# សូមអរគុណសម្រាប់ការយកចិត្តទុកដាក់ស្តាប់

សហព័ន្ធមេធាវីជប៉ុន មជ្ឈមណ្ឌលកម្មសិទ្ធិបញ្ញា ប្រធានPTអន្តរជាតិ
មេធាវី ហ៊ីរ៉ាណូ ស៊ីហ្គិតូស៊ី (Hirano Shigetoshi)
ក្រុមហ៊ុនមេធាវី ការិយាល័យច្បាប់អូអិបាស៊ី
e-mail: hirano@ohebashi.com